អគ្គិសនីកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងថ្លៃបន្តចរន្ត និងប្រាក់កក់ លើការសុំបន្តចរន្តអគ្គិសនី ពីបណ្តាញសាធារណៈ (១)

| អាំងតង់ស៊ីតេ ស្នើសុំប្រើប្រាស់ ph x A | ប្រភេទអតិថិជន " លំនៅដ្ឋាន - អគាររដ្ឋបាល " | | | ប្រភេទអតិថិជន " អាជីវកម្ម - សិប្បកម្ម " | | | ប្រភេទអតិថិជន " ផ្ទះជួលឱ្យបរទេស-ស្ថានទូត-សណ្ឋាគារ " | | | រយៈពេល ផ្តល់សេវា (២) |
|---|---|---|---|---|---|---|---|---|---|---|
| | ថ្លៃភ្ជាប់ចរន្ត (រៀល) | ថ្លៃប្រាក់កក់ (រៀល) | ទឹកប្រាក់សរុប (រៀល) | ថ្លៃភ្ជាប់ចរន្ត (រៀល) | ថ្លៃប្រាក់កក់ (រៀល) | ទឹកប្រាក់សរុប (រៀល) | ថ្លៃភ្ជាប់ចរន្ត (រៀល) | ថ្លៃប្រាក់កក់ (រៀល) | ទឹកប្រាក់សរុប (រៀល) | |
| **1 x 5** | 31,000 | 28,000 | **59,000** | 31,000 | 111,000 | **142,000** | 31,000 | 148,000 | **179,000** | ១៥ ថ្ងៃ ថ្ងៃការងារ (៣) |
| **1 x 10** | 62,000 | 56,000 | **118,000** | 62,000 | 222,000 | **284,000** | 62,000 | 296,000 | **358,000** | |
| **1 x 20** | 228,000 | 111,000 | **339,000** | 228,000 | 444,000 | **672,000** | 228,000 | 592,000 | **820,000** | |
| **1 x 32** | 368,000 | 356,000 | **724,000** | 368,000 | 711,000 | **1,079,000** | 368,000 | 948,000 | **1,316,000** | |
| **1 x 63** | 736,000 | 700,000 | **1,436,000** | 736,000 | 1,399,000 | **2,135,000** | 736,000 | 1,865,000 | **2,601,000** | |
| **3 x 32** | 1,104,000 | 1,066,000 | **2,170,000** | 1,104,000 | 2,132,000 | **3,236,000** | 1,104,000 | 2,842,000 | **3,946,000** | ៤៥ ថ្ងៃ ថ្ងៃធម្មតា (៤) |
| **3 x 40** | 1,368,000 | 1,332,000 | **2,700,000** | 1,368,000 | 2,664,000 | **4,032,000** | 1,368,000 | 3,552,000 | **4,920,000** | |
| **3 x 63** | 2,208,000 | 2,098,000 | **4,306,000** | 2,208,000 | 4,196,000 | **6,404,000** | 2,208,000 | 5,595,000 | **7,803,000** | |
| **3 x 100** | 3,300,000 | 3,330,000 | **6,630,000** | 3,300,000 | 6,660,000 | **9,960,000** | 3,300,000 | 8,880,000 | **12,180,000** | |

ថ្ងៃ **ពុធ ២រោច** ខែ **ជេស្ឋ** ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី **១៩** ខែ **មិថុនា** ឆ្នាំ២០១៩

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**អគ្គនាយកអគ្គិសនីកម្ពុជា**

កែវ_រតនៈ

**<u>កំណត់ចំណាំ:</u>**

(១). អតិថិជនមិនត្រូវបង់ប្រាក់លើសពីតារាងខាងលើឡើយ ។

(២). រយៈពេលផ្តល់សេវាគឺគិតចាប់ពីថ្ងៃទទួលពាក្យ រហូតដល់ថ្ងៃភ្ជាប់ចរន្តដោយមិនគិតពីការយឺតយូរបស់អ្នកស្នើសុំដូចជា៖

- បំពេញឯកសារមិនគ្រប់តាមការតម្រូវ ដូចក្នុងទម្រង់ពាក្យសុំបន្តចរន្តអគ្គិសនី និង/ឬ យឺតយូរក្នុងការមកចុះហត្ថលេខា លើកិច្ចសន្យាជាវចរន្ត និង/ឬពន្យាពេលក្នុងការបង់ប្រាក់ ។
- ពុំទាន់មានសម្ភារៈដែលជាបន្ទុករបស់អតិថិជន ។

(៣). ថ្ងៃការងារ គិតពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាកដែលប្រកាសដោយអនុក្រឹត្យនៃរាជរដ្ឋាភិបាល ។

(៤). ថ្ងៃធម្មតា គិតទាំងថ្ងៃឈប់ និងថ្ងៃការងារ ។

**<u>បញ្ជាក់:</u>**

- ករណីមានការយឺតយ៉ាវជាងរយៈពេលកំណត់ខាងលើ អគ្គិសនីកម្ពុជា នឹងផ្តល់ជូនព័ត៌មានដល់អតិថិជនជាលាយល័ក្ខណ៍អក្សរ ។
- ការបន្តចរន្តថ្មី ឬតម្លើងកម្លាំង អាចផ្តល់ជូនបានលុះត្រា បំណុលថ្លៃភ្លើងនៅទីតាំងនោះ ត្រូវបានទូទាត់ជាមុនសិន ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៩៩៦១ អក.១៥

# គោលការណ៍

## ស្តីពីការយកកម្រៃ សេវា ផ្តាច់-ភ្ជាប់ ការផ្គត់ផ្គង់អគ្គិសនីជូនអតិថិជន ប្រើប្រាស់អគ្គិសនី ពីអគ្គិសនីកម្ពុជា នៅក្នុងប្រព័ន្ធផ្គត់ផ្គង់ភ្នំពេញ និងនៅតាមបណ្តាអង្គភាពអគ្គិសនីខេត្ត ចំណុះឲ្យអគ្គិសនីកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យ ជស/រកត/០៣៩៦/១០របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសហនុ ចុះ ថ្ងៃទី ០៩/០៣/១៩៩៦ ស្តីពីការបង្កើតអគ្គិសនីកម្ពុជា ជាក្រុមហ៊ុនទទួលខុសត្រូវ មានកំណត់មួយរបស់រដ្ឋ ។

- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/០៨០៨/៩៨៧ របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហមុនី ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា ។

- បានឃើញ សេចក្តីសម្រេចលេខ ៤៦១ សរ.១៥ អអក របស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការកំណត់ថ្លៃភ្ជាប់ចរន្ត ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី និងថ្លៃសេវាបម្រើអតិថិជន ដែលអ្នកផ្តល់សេវាអគ្គិសនីត្រូវអនុវត្ត ក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញ ភាពចាំបាច់ ដើម្បីធានានូវប្រសិទ្ធិភាព នៃការធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីជូនអតិថិជន

**ប្រការ ១** កំណត់យកថ្លៃសេវាផ្តាច់-ភ្ជាប់ការផ្គត់ផ្គង់ចរន្តអគ្គិសនី លើទីតាំងប្រើប្រាស់អគ្គិសនីដែលជាប់ជំពាក់ថ្លៃប្រើប្រាស់អតិថិជនហួសកាលកំណត់ នៅក្នុងវិក្កយបត្រប្រើប្រាស់ប្រចាំខែៈ

- **អតិថិជនតង់ស្យុងទាប** ១០,០០០ រៀល ក្នុង ១ដង
- **អតិថិជនតង់ស្យុងមធ្យម** ២០,០០០ រៀល ក្នុង ១ដង

**ប្រការ ២** កំណត់យកថ្លៃសេវាសុំផ្អាកការប្រើប្រាស់អគ្គិសនីបណ្តោះអាសន្ន

- គ្រប់ទំហំអំពែរ និងគ្រប់ប្រភេទអតិថិជន ៤០,០០០ រៀល ក្នុង ១ដង

**ប្រការ៣** កំណត់យកថ្លៃសេវាពិនិត្យផ្ទៀងផ្ទាត់លេខអំណាននាឡិកាស្ទង់( ករណីពិនិត្យឃើញថាស្រង់លេខអំណាននាឡិកាស្ទង់ត្រឹមត្រូវ អ្នកប្រើប្រាស់ត្រូវបង់ថ្លៃសេវាផ្ទៀងផ្ទាត់។ករណីពិនិត្យឃើញថាស្រង់លេខអំណាននាឡិកា ស្ទង់ខុស អ្នកប្រើប្រាស់ ពុំតម្រូវឲ្យបង់ថ្លៃសេវាទេ ។

- ប្រភេទលំនៅដ្ឋានធម្មតា ៥,០០០ រៀល ក្នុង ១ដង
- ប្រភេទក្រៅលំនៅដ្ឋានធម្មតា ១០,០០០ រៀល ក្នុង ១ដង

**ប្រការ ៤** ចំណូលនៃសេវានេះ ត្រូវបង់ចូលបេឡានៃអង្គភាពនីមួយៗទាំងស្រុង ។

**ប្រការ ៥** អង្គភាពនីមួយៗ ត្រូវរៀបចំបែបបទតាមគោលការណ៍ គណនេយ្យ-ហិរញ្ញកិច្ច ដកចំណូលសេវាខាងលើសំរាប់ឧបត្ថមដល់ការបំពេញភារកិច្ច របស់អង្គភាពផ្ទាល់ ចំនួន ៦០% នៃចំណូលសេវាប្រចាំខែ ។

**ប្រការ ៦** សេចក្តីសម្រេចនេះ មានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ រហូតដល់មានការសម្រេចជាថ្មី និងនិរាករណ៍ នូវសេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ... ឆ្នាំ ២០១៥

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**